# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## អំពីអគតិ៤យ៉ាង ដែលសំដែងក្នុងគម្ពីរ
## ព្រះពុទ្ធសាសនា

**Website: www.hoksavann.org**

ថ្ងៃទី១២ ធ្នូ ២០០៤

ពាក្យថា <អគតិ> ជានាមសព្ទ ចេញមកពីភាសាបាលីនិងសំស្ក្រឹត ប្រែថាការលំអៀង ។ អគតិឬអគតិធម៌ ការលំអៀងនោះមាន៤យ៉ាង គឺ១- ឆន្ទាគតិ ការលំអៀងដោយស្រឡាញ់, ២-ទោសាគតិ ការលំអៀងព្រោះស្អប់, ៣-ភយាគតិ ការលំអៀងព្រោះភ័យខ្លាច, ៤-មោហាគតិ ការលំអៀងព្រោះល្ងង់ពុំដឹងការពិត ។ អគតិធម៌ទាំង៤នេះច្រើនធ្លាក់ទៅលើចៅក្រមឬតុលាការកាត់សេចក្តីដែលពុំមានយុត្តិធម៌ ឬធ្លាក់ទៅលើអ្នកមានអំណាចដែលមានចិត្តលំអៀង ។

១- ឆន្ទាគតិ លំអៀងព្រោះស្រឡាញ់ ដូចចៅក្រមឬមេធាវីជាអ្នកកាត់សេចក្តី បានពិនិត្យមើលសំណុំរឿងនិងបានស្តាប់សាក្សី ដឹងឮសព្វគ្រប់ទៅ ត្រូវកាត់ឲ្យកូនក្តីម្ខាងនោះចាញ់ ប៉ុន្តែកូនក្តីនោះត្រូវជាសាច់ញាតិបងប្អូន ឬជាមិត្តសម្លាញ់របស់ខ្លួន ឬដោយសារមេធាវីនោះបានទទួលសំណូកសូកប៉ាន់ ក៏កាត់ឲ្យឈ្នះទៅវិញ ។ ពាក្យខ្មែរពោលថា យល់ញាតិឃ្លាតច្បាប់ នោះហៅថាលំអៀងដោយស្រឡាញ់ ។

២- ទោសាគតិ លំអៀងដោយស្អប់ ដូចចៅក្រមឬមេធាវីកាត់ក្តីប៉ះទៅលើកូនក្តីម្ខាងដែលខ្លួនស្អប់ ឬជាគូសត្រូវរបស់ខ្លួនដែលខ្លួនត្រូវកំចាត់ ។ កូនក្តីនោះ បើតាមសំណុំរឿងជាអ្នកត្រឹមត្រូវគ្មានកំហុសអ្វីសោះ ប៉ុន្តែត្រូវកាត់ឲ្យចាញ់ដោយសារការស្អប់របស់ខ្លួន ។ មួយទៀត មនុស្សនោះគ្មានកំហុសអ្វីសោះ ប៉ុន្តែរកលេសចោទឲ្យមានកំហុសដោយការព្យាបាទ ដូចពាក្យខ្មែរពោលថា ឆ្កែមិនឆ្កួតពោលថាឆ្កែឆ្កួត ដើម្បីយកទោសម្លាប់, ចោរលួចយរួចខ្លួនម្ចាស់ទ្រព្យជាប់គុក, អ្នកសម្លាប់គេមានភស្តុតាងច្បាស់លាស់រួចខ្លួនអ្នករងគ្រោះឡើងតុលាការកាត់ក្តី នេះហៅថាលំអៀងព្រោះស្អប់ ។

៣- ភយាគតិ លំអៀងដោយភ័យខ្លាច គឺខ្លាចអំណាចបុណ្យស័ក្តិ ខ្លាចអំណាចទ្រព្យសម្បត្តិ ។ សេចក្តីថា ចៅក្រមដែលគ្មានឧត្តមគតិគ្មានឯករាជ្យ ធ្វើតាមតែបញ្ជារបស់អ្នកមានអំណាចបុណ្យស័ក្តិ និងរបស់អ្នកមានទ្រព្យសម្បត្តិ ។ មេធាវីឬចៅក្រមដែលបុំអាចអនុវត្តស្របតាមវិជ្ជាជីវៈរបស់ខ្លួននេះ ដោយភ័យខ្លាចគ្រោះថ្នាក់ដល់ខ្លួន បើពុំធ្វើតាមបញ្ជារបស់អ្នកមានអំណាចទេ នេះហៅថាលំអៀងព្រោះភ័យខ្លាច ។

៤- មោហាគតិ លំអៀងព្រោះល្ងង់ដោយមានចំណេះវិជ្ជាតិចហើយគេឲ្យធ្វើចៅក្រមកាត់សេចក្តី ឬកាត់សេចក្តីដោយពុំបានស៊ើបអង្កេត ពុំបានរកភស្តុតាងឲ្យបានច្បាស់លាស់ ។ ចៅក្រមល្ងង់ផងគ្មានមេត្តាធម៌ផងមានគ្រោះថ្នាក់ដល់ជាតិខ្លាំងណាស់ ព្រោះពុំអាចរកយុត្តិធម៌ជូនប្រជាព-លរដ្ឋបាន ។ ចៅក្រមល្ងង់ហើយគ្មានជំហររឹងប៉ឹងផង ឆាប់ធ្វើតាមបញ្ជារបស់អ្នកកាន់អំណាចណាស់ ។ នេះហៅថាលំអៀងដោយល្ងង់ ។

អគតិធម៌ទាំង៤នេះ ជាដំណើរមិនប្រកបដោយធម៌ជាដំណើរនៃសេចក្តីវិនាស ជាដំណើរនៃការរំលោភសិទ្ធិមនុស្ស ព្រោះតែការកាត់សេចក្តីមនុស្សល្អឲ្យមានទោស ។ ពុទ្ធសាសនាសំដែងថា តុលាការដែលប្រកបដោយអគតិធម៌នេះមានទោសក្នុងបច្ចុប្បន្ន ហើយស្លាប់ទៅនឹងធ្លាក់ទៅសោយទុក្ខក្នុងនរកដូចគេច្រានទម្លាក់ ។ តុលាការជាអំណាចទី៣នៃប្រទេសដែលកាន់របបប្រជាធិបតេយ្យ បើតុលាការមិនប្រកាន់គោលជំហរយុត្តិធម៌ទេ ប្រទេសនោះនឹងទៅជាប្រទេសផ្តាច់ការ ព្រោះអ្នកមានអំណាចធ្វើខុសតុលាការ ពុំអាចកាត់ទោស ហើយកាត់ទោសបានតែប្រជាពលរដ្ឋតូចតាចឥតបុណ្យឥតស័ក្តិឥតទ្រព្យសម្បត្តិប៉ុណ្ណោះ ។ អគតិធម៌ទាំង៤នេះជាផ្លូវនៃអបាយ ប្រែថាមិនចំរើនជាហេតុនាំឲ្យវិនាស គឺអ្នកប្រព្រឹត្តនឹងមានទោសក្នុងបច្ចុប្បន្ន ហើយស្លាប់ទៅនឹងត្រូវទៅសោយទុក្ខក្នុងនរកទៀត ។០៚